**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ម្រ.ក/លេខ ០៥.០៨៥/០៩ គ.ជ.ប.អគ្គ.ពស**

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩

# ចំនួនបណ្តឹងក្នុងដំណាក់កាលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

(គិតចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩)

ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ គណបក្សនយោបាយចំនួន ៤ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះ បានធ្វើសកម្មភាពឃោសនាតាមវិធីរៀងៗខ្លួន ដោយមានការជួបប្រជុំសំណេះសំណាលជាមួយសកម្មជនគណបក្សនយោបាយរបស់ខ្លួននៅតាមទីស្នាក់ការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ជួបសំណេះសំណាលជាមួយសកម្មជន (ក្រុមប្រឹក្សាឃុំ សង្កាត់) នៅតាមផ្ទះ និងមានការចាក់ឧត្ឋោសនសព្ទនៅតាមទីស្នាក់ការគណបក្សនយោបាយមួយចំនួន ។

គណបក្សប្រជាជនកម្ពុជា បានហែក្បួនឃោសនានៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមប្រមាណ ១,២៥០នាក់ ដោយមានរថយន្តប្រមាណ ៧០ គ្រឿង និងម៉ូតូប្រមាណ ៤៥គ្រឿង ។ នៅខេត្តក្រចេះ គណបក្សប្រជាជនកម្ពុជា បានហែក្បួនឃោសនា ដោយរថយន្តប្រមាណ ២០ គ្រឿង និងម៉ូតូ ៣០គ្រឿង ។

ក្នុងរយៈពេល ១១ថ្ងៃ នៃការឃោសនាបោះឆ្នោតនេះ បណ្តឹង ចំនួន ៤ ត្រូវបានប្តឹងដោយគណបក្ស សម រង្ស៊ី រួមមាន នៅរាជធានីភ្នំពេញ ចំនួន ៣បណ្តឹង និងនៅខេត្តស្ទឹងត្រែង ចំនួន ១បណ្តឹង ។ គណបក្ស សម រង្ស៊ី បានប្តឹងលោក **លី វ៉ាម៉ន** លោក **លេង ផាលី** ពីបទទិញសន្លឹកឆ្នោត នៅសង្កាត់ភ្នំពេញថ្មី និងសង្កាត់ទឹកថ្លា រាជធានីភ្នំពេញ ។ ចំណែកបណ្តឹងនៅខេត្តស្ទឹងត្រែង គណបក្ស សម រង្ស៊ី បានប្តឹងលោក **ញ៉ែម សាម៉ន** ពីបទប្រើប្រាស់អាគារ និងការិយាល័យរបស់រដ្ឋធ្វើការឃោសនាបោះឆ្នោត ។ បណ្តឹងទាំងនេះត្រូវបានធ្វើការដោះស្រាយដោយគណៈកម្មាធិការរាជធានី/ខេត្តរៀបចំការបោះឆ្នោត (គធ/ខប) តាមនីតិវិធី ។

សូមរំលឹកថា ការឃោសនាបោះឆ្នោតបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៩ ។ GND